**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៥៩,៧៣៤ ដុល្លារអាមេរិក សម្រាប់គម្រោងពង្រីកបណ្តាញទឹកស្អាត



ក្រោមគ្រោងការ ណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៥៩,៧៣៤ ដុល្លាអាមេរិក ដល់វិទ្យាស្ថានសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ - ភ្នំពេញសម្រាប់គម្រោងពង្រីកបណ្តាញទឹកស្អាតរបស់រដ្ឋាករទឹកតាំងក្រសាំង ខេត្តកំពង់ធំ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយឯកឧត្តម ម៉ាសាហ្វូមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ស្រី Elisa Lieke COENEGRACHTS តំណាងប្រចាំប្រទេសនៃវិទ្យាស្ថានសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ - ភ្នំពេញ នៅស្ថានទូតជប៉ុន។



វិទ្យាស្ថានសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ - ភ្នំពេញ ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយនឹងអនុវត្តគម្រោងពង្រីកបណ្តាញទឹកស្អាតប្រវែង ៦,១៣៨ម៉ែត្រក្នុងភូមិពីរនៅក្នុងឃុំប្រាសាទស្រុកសន្ទុកខេត្តកំពង់ធំ។ ជាផ្នែកមួយនៃគម្រោងផងដែរ វគ្គបណ្តុះបណ្តាលរយៈពេល២សប្តាហ៍ស្តីពីសុខភាព និងអនាម័យនឹងត្រូវបានធ្វើឡើងក្នុងភូមិទាំងពីរដោយមានការចែកជូនសៀវភៅណែនាំចំនួន៥០០ក្បាល។ យើងសង្ឃឹមថា ប្រជាជនក្នុងភូមិជាង២,០០០នាក់នឹងទទួលបានទឹកស្អាតមានសុវត្ថិភាពពេញមួយឆ្នាំៗ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ

១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន  ៤៦៣គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*